ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# មិនមានករណីជាសះស្បើយ និងមិនមានករណីវិជ្ជមានវីរុសកូវីដ-១៩ ថ្មី

## នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២០

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ឲ្យបានជ្រាបពីស្ថានភាពជំងឺកូវីដ- ១៩ នៅកម្ពុជា មានដូចខាងក្រោមនេះ ៖

**១. ស្ថានភាពជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ៖**

គិតត្រឹមម៉ោង ០៧:០០ព្រឹក ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០ ស្ថានភាពជំងឺកូវីដ-១៩ នៅកម្ពុជា មាន៖

-ចំនួនអ្នកព្យាបាលជាសះស្បើយសរុបទូទាំងប្រទេស មានចំនួន **២៧៤នាក់** (ស្មើនឹង ៩៩,៦៤% ធៀបនឹងចំនួនអ្នកមានវីរុសកូវីដ-១៩ទាំងអស់) នៅក្នុងចំនួននេះ មានស្រី ៥៤នាក់ និងប្រុស ២២០នាក់

- អ្នកមានវីរុសកូវីដ-១៩ មានចំនួនសរុប **២៧៥នាក់** (ស្រ្តី ៥៤នាក់ និងប្រុស ២២១នាក់)

- អ្នកកំពុងសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត រាជធានីភ្នំពេញ ចំនួន **០១នាក់** ។

**២. ករណីជាសះស្បើយ ៖** មិនមានអ្នកជាសះស្បើយ នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២០។

**៣. ករណីវិជ្ជមានវីរុសកូវីដ-១៩ ៖** មិនមានអ្នកវិជ្ជមានវីរុសកូវីដ-១៩ ថ្មី នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២០។

**៤. ស្ថានភាពក្នុងកំឡុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌ ៖**

ក្រោមការដឹកនាំដ៏ឈ្លៀសវៃប្រកបដោយគតិបណ្ឌិត និងបេះដូងមនុស្សធម៌របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានធ្វើឲ្យប្រទេសជាតិមានសុខសន្តិភាពពេញលេញ និងការអភិវឌ្ឍ ដែលបានបង្កលក្ខណៈឲ្យបងប្អូនប្រជាពលរដ្ឋជាច្រើន បានចូលរួមប្រារព្ធពិធីកាន់បិណ្ឌ និងភ្ជុំបិណ្ឌក្នុងរយៈពេលកន្លងមកនេះ ព្រមទាំងបានដើរលេងកំសាន្តដោយសេរីប្រកបដោយសេចក្តីសប្បាយរីករាយផងដែរ។ នៅក្នុងបរិបទនៃការប្រយុទ្ធនឹងជំងឺកូវីដ-១៩ ក្រោមការដឹកនាំ និងដាក់ចេញនូវវិធានការទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ បានទាន់ពេលវេលារបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានធ្វើឲ្យស្ថានភាពជំងឺកូវីដ-១៩ មិនឲ្យមានការរាតត្បាតក្នុងទ្រង់ទ្រាយធំ និងមិនទាន់មានការចម្លងចូលក្នុងសហគមន៍នៅឡើយ មកទល់ពេលនេះ។ ទោះជាយ៉ាងនេះក្តី សូមបងប្អូនប្រជាពលរដ្ឋទាំងអស់ ត្រូវចេះរៀនសូត្ររការរស់នៅជាមួយនឹងវត្តមានរបស់វីរុសកូវីដ-១៩ "រស់នៅធម្មតាតាមបែបគន្លងថ្មី" ដោយកែប្រែទម្លាប់របស់ខ្លួនឲ្យមានការថែរក្សាសុខភាពឲ្យបានល្អប្រសើរ ដើម្បីចៀសផុតពីការចម្លងជំងឺឆ្លងនានា ជាពិសេសពីការចម្លងវីរុសកូវីដ-១៩ ដោយត្រូវនាំគ្នាចូលរួមអនុវត្តន៍ អនាម័យដៃស្អាតជានិច្ច ពាក់ម៉ាស់នៅក្នុងករណីចាំបាច់ និងរក្សាគម្លាតសុវត្ថិភាពបុគ្គលពីមួយម៉ែត្រកន្លះឡើងទៅ ដែលជាវិធានការសាមញ្ញៗ តែងតែមានការណែនាំឲ្យអនុវត្តន៍ជាប្រចាំដោយក្រសួងសុខាភិបាល។

ក្នុងរយៈពេលនៃថ្ងៃកាន់បិណ្ឌ និងភ្ជុំបិណ្ឌ កន្លងទៅនេះ ក្រសួងសុខាភិបាល បានធ្វើការអំពាវនាវ ណែនាំ និងតាមដានស្ថានភាពនៃការចម្លងវីរុសកូវីដ-១៩ដោយយកចិត្តទុកដាក់ តាមរយៈបណ្តាញប្រព័ន្ធសុខាភិបាលនៅទូទាំងប្រទេសឃើញថា៖ *"មិនទាន់មានករណីចម្លងវីរុសកូវីដ-១៩ ថ្មី កើតមានឡើងនៅក្នុងប្រទេស (Local transmission) និងមិនទាន់មានការចម្លងចូលក្នុងសហគមន៍ (Community transmission) នៅឡើយទេ"* ដែលស្ថានភាពនេះ គឺជាជោគជ័យមួយវគ្គទៀតហើយ បន្ទាប់ពីស្ថានភាពមិនមានការចម្លងវីរុសកូវីដ-១៩ ក្នុងកំឡុងពេលឈប់សម្រាកសម្រាប់សងថ្ងៃឈប់សម្រាកបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរ កាលពីខែសីហាកន្លងទៅនេះ។



ទីស្តីការក្រសួងសុខាភិបាល ដីឡូតិ៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ឯកឧត្តមសាស្ត្រាចារ្យ **ម៉ម ប៊ុនហេង** រដ្ឋមន្ត្រីក្រសួងសុខាភិបាល សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់អាជ្ញាធរថ្នាក់ក្រោមជាតិ អាជ្ញាធរមានសមត្ថកិច្ច និងផ្នែកពាក់ព័ន្ធទាំងអស់ ជាពិសេសថ្នាក់ដឹកនាំ បុគ្គលិក-មន្ត្រី សុខាភិបាលគ្រប់លំដាប់ថ្នាក់ (ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) និងក្រុមគ្រូពេទ្យជួរមុខទាំងអស់នៅទូទាំងប្រទេស ដែលបានខិតខំអនុវត្តន៍ការតាមដានស្រាវជ្រាវ ពិនិត្យ និងផ្តល់សេវាសុខាភិបាល ជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ប្រកបដោយការលះបង់ខ្ពស់ យកចិត្តទុកដាក់គោរពក្រមសីលធម៌វិជ្ជាជីវៈសុខាភិបាល និងមានកិច្ចសហការអន្តរវិស័យបានល្អប្រសើរគួរជាទីមោទនៈ ដែលបានចូលរួមចំណែកក្នុងការទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងកំឡុងពេលកាន់បិណ្ឌ និងភ្ជុំបិណ្ឌកន្លងទៅនេះ។

ទោះជាយ៉ាងនេះក្តី ក្រសួងសុខាភិបាល សូមធ្វើការអំពាវនាវហើយអំពាវនាវទៀត សូមលោកអ្នក មេត្តាកុំភ្លេចថា៖ ***ការដែលរកមិនទាន់ឃើញអ្នកឆ្លងវីរុសកូវីដ-១៩ ថ្មី នៅក្នុងប្រទេស មិនមែនមានន័យថា មិនមានវីរុសកូវីដ-១៩ ឬក៏ការរាតត្បាតនៃវីរុសនេះ បានចប់ហើយនោះទេ*** ហើយយើងទាំងអស់គ្នា មិនត្រូវសន្និភាពនិយមជាមួយនឹងវីរុសនេះឲ្យសោះ។ ផ្ទុយទៅវិញ វីរុសដ៏កាចសាហាវនេះ កំពុងតែចរាចរពេញទំហឹងនៅតាមបណ្តាប្រទេសនៅលើសាកលលោក និងនៅក្នុងតំបន់ ជាពិសេសប្រទេសជិតខាងកម្ពុជា ក៏នៅមានវីរុសនេះ ចរាចរនៅឡើយដែរ។ ដូច្នេះ ហានិភ័យនៃការចម្លងចូលមកក្នុងប្រទេសកម្ពុជា នៅតែមាននៅឡើយទេ ហើយលទ្ធភាពនៃការចម្លងចូលក្នុងសហគមន៍ ក៏នៅតែមានដែរ ប្រសិនបើយើងមានការធ្វេសប្រហែស។ ដូច្នេះ សូមលោកអ្នក "***បន្តការពារខ្លួនពីការចម្លងវីរុសកូវីដ-១៩ ឲ្យបានខ្ជាប់ខ្ជួន ពីព្រោះវីរុសកូវីដ-១៩ នេះ ស្ថិតនៅក្បែរយើងនៅឡើយទេ ដែលការចម្លងអាចនឹងកើតមានឡើងនៅគ្រប់ពេលវេលា គ្រប់កាលទេសៈ និងគ្រប់ទីកន្លែងទាំងអស់***"។

ក្រសួង ក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺឆ្លងសហរដ្ឋអាមេរិក វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា វិទ្យាស្ថានជាតិសុខភាពសាធារណៈ និងមន្ទីរពិសោធន៍នៃមន្ទីរពេទ្យខេត្តសៀមរាប ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ-១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ-១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេសប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៨៨៨ ៥៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃអាទិត្យ ៣កើត ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២០

វេជ្ជបណ្ឌិត **ឱ វណ្ណឌីន**

រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា



ទីស្តីការក្រសួងសុខាភិបាល ដីឡូត៍លេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩